ក្រសួងយុត្តិធម៌
លេខ ៣២៥ រប.៦១០៦-៩៤

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

**លោក ប្រធានតុលាការ និងព្រះរាជអជ្ញាអមតុលាការ ក្រុងភ្នំពេញ**

**សូមជ្រាប។**

**កម្មវត្ថុ:** ស្តីពីការបញ្ជូនជនត្រូវចាប់ខ្លួន ឃាត់ខ្លួន មស្ថាប័នអយ្យការ និងតុលាការដោយហួសរយៈពេលកំណត់ក្នុងច្បាប់ ។

**យោង:** កំណត់ហេតុចុះថ្ងៃទី១២-១២-៩៣ របស់ចៅក្រម និងព្រះរាជអាជ្ញាអមតុលាការក្រុងភ្នំពេញ ។

ខ្ញុំសូមជម្រាបលោកថា ក្នុងបញ្ហាដែលមន្ត្រីនគរបាលបានបញ្ជូនជនត្រូវចាប់ខ្លួន ឃាត់ខ្លួនមកស្ថាប័នអយ្យការ និងតុលាការដោយហួសរយៈពេលកំណត់៤៨ម៉ោងក្នុងច្បាប់ច្បាប់នោះ គឺជាកំហុសមួយដោយឡែករបស់មន្ត្រីនគរបាល ដែលអាចត្រូវចោទប្រកាន់អំពីបទឃុំខ្លួនខុសច្បាប់ដោយអនុលោមតាមច្បាប់ព្រហ្មទណ្ឌអន្តរកាលតាមមាត្រា ១៣,២២,៥៧ និងមាត្រា ៤៧ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

កាលបើមន្ត្រីនគរបាលបញ្ជូនជនដែលត្រូវចាប់ខ្លួន ឃាត់ខ្លួននោះមកទោះបីមានការហួសរយៈពេលកំណត់ក្នុងច្បាប់ក្តី ព្រះរាជអាជ្ញាត្រូវតែអនុវត្តតាមមាត្រា ៦៣ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។ព្រះរាជអាជ្ញាត្រូវពិនិត្យមើលតើអំពើប្រព្រឹត្តរបស់ជននោះចូលជាបទព្រហ្មទណ្ឌឬទេ តើមានពិរុទ្ធភាពឬគ្មានពិរុទ្ធភាព ។ព្រះរាជអាជ្ញាក្រោយពីបានសួរយកចម្លើយជននោះសព្វគ្រប់ហើយ ឃើញថាបន្ទុកមិនត្រូវធ្លាក់ទៅលើជននោះទេ នោះត្រូវឲ្យគេរួចខ្លួនដោយឯកឯង មិនត្រូវចេញលិខិតស្នាមអ្វីឡើយ ។ ប៉ុន្តែក្រោយពីការសួរយកចម្លើយ បើព្រះរាជអាជ្ញាពិនិត្យឃើញថាមានវិមតិសង្ស័យលើជនណាមួយនោះ ព្រះរាជអាជ្ញាត្រូវសេចក្តីសន្និដ្ឋានបញ្ជូនរឿង និងជនជាប់ចោទទាក់ទិននោះទៅចៅក្រមស៊ើបអង្កេតចាត់ការងតាមច្បាប់ ឬមួយបើពិនិត្យឃើញថារឿងនោះមានធាតុផ្សំគ្រប់គ្រាន់មូលសព្វគ្រប់ហើយហើយជាបទល្មើសមជ្ឈិម នោះត្រូវអនុវត្តតាមមាត្រា ៦១ នៃច្បាប់នីតិវិធីព្រហ្មទណ្ឌក៏បាន ។

សូមលោកអនុវត្តតាមការណែនាំខាងលើនេះឲ្យបានល្អ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៤

**រដ្ឋមន្ត្រី**

**ចែម ស្ងួន**

<u>ចម្លងជូន</u>

-ប្រធានតុលាការគ្រប់ខេត្ត ក្រុង

-ព្រះរាជអាជ្ញាអមតុលាការគ្រប់ខេត្ត ក្រុង